# ការវាយតម្លៃដាក់ពិន្ទុ វិជ្ជាសម្បទា បំណិនសម្បទា និង ចរិយាសម្បទា

លោក ប៊ុត សុភាន់

អនុប្រធាននាយកដ្ឋានមធ្យមសិក្សាចំណោ

## គ. ការដាក់ពិន្ទុ លើវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា

ការដាក់ពិន្ទុប្រចាំខែ និងប្រចាំឆមាស ត្រូវបន្តអនុវត្តតាមគោលការណ៍ណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា (នាយកដ្ឋានកិច្ចការប្រឡង)។ ចំពោះការដាក់ពិន្ទុប្រចាំឆ្នាំ ត្រូវបែកចេញជា ៣ផ្នែកដោយផ្ដោតលើវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា និងត្រូវអនុវត្តដូចខាងក្រោម៖

- ពិន្ទុវិជ្ជាសម្បទា ត្រូវយកពិន្ទុមធ្យមភាគពីមុខវិជ្ជាសិក្សាគោលសរុបប្រចាំឆ្នាំ ហើយគុណនឹង ៨០% ដើម្បីបានពិន្ទុសរុបលើការវាយតម្លៃចំណេះដឹង ឬសមត្ថភាពសិស្ស

- ពិន្ទុបំណិនសម្បទា ត្រូវធ្វើការវាយតម្លៃលើការអនុវត្តកម្មវិធីក្រៅម៉ោងសិក្សា តាមសេចក្ដីណែនាំលេខ២៩ អយក.សណន ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ ២០២៤ ដោយផ្ដល់ពិន្ទុ១០% លើការវាយតម្លៃបំណិនរបស់សិស្ស
- ពិន្ទុចរិយាសម្បទា ត្រូវធ្វើការវាយតម្លៃលើការអនុវត្តកម្មវិធីលើកកម្ពស់សីលធម៌ គុណធម៌ និង ឥរិយាបថ ដោយដាក់ពិន្ទុលើ ស្អាត របៀប សុភាព ទៀងពេល និងសមាធិ ដោយផ្ដល់ពិន្ទុ ១០% សម្រាប់ការវាយតម្លៃចរិយាធម៌របស់សិស្ស
- ការដាក់ពិន្ទុត្រូវមានមូលវិចារដែលបញ្ជាក់ពីចំណុចល្អ និងចំណុចខ្វះខាតរបស់សិស្ស។<u>បញ្ជាក់</u>៖ឧបករណ៍វាយតម្លៃការអប់រំចរិយាសម្បទាដូចមានក្នុង (ឧបសម្ព័ន្ធទី២)។

## ឧទាហរណ៍ ៖

ការគណនាពិន្ទុវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា របស់សិស្ស " ក "

តារាងលទ្ធផលនៃការសិក្សា ( ដកចេញពីសៀវភៅសិក្ខាគារិក )

| វិញ្ញាសា | ឆមាសទី១ | ឆមាសទី២ |
|---|---|---|
| គណិតវិទ្យា | ៧០ | ៨២ |
| តែងសេចក្តី | ៣២ | ៣១ |
| ការសរសេរតាមអាន | ៣៥ | ២៨ |
| រូបវិទ្យា | ២៤ | ២០ |
| គីមីវិទ្យា | ២០ | ២៤ |
| ជីវវិទ្យា | ១៧ | ២០ |
| ផែនដី និងបរិស្ថានវិទ្យា | ១៥ | ២២ |
| សីលធម៌-ពលរដ្ឋវិទ្យា | ២៥ | ២១ |
| ភូមិវិទ្យា | ២៣ | ២៥ |
| ប្រវត្តិវិទ្យា | ២៤ | ២៣ |
| ភាសាបរទេស | ៣១ - ២៥ = ៦ | ៣៣ - ២៥ = ៨ |
| ផលបូកពិន្ទុប្រឡងឆមាស | ២៩១ | ៣០៤ |
| មធ្យមភាគពិន្ទុប្រឡងឆមាស | ៣៤.៦៤ | ៣៦.១៩ |
| មធ្យមភាគពិន្ទុខែប្រចាំឆមាស | ៣៥.២៤ | ៣៧.២៣ |
| មធ្យមភាគពិន្ទុប្រចាំឆមាស | ៣៤.៩៤ | ៣៦.៧១ |
| មធ្យមភាគពិន្ទុប្រចាំឆ្នាំ | ៣៥.៨៣ | |

គ.១. ៨០% នៃមធ្យមភាគពិន្ទុវិជ្ជាសម្បទាប្រចាំឆ្នាំ = មធ្យមភាគពិន្ទុប្រចាំឆ្នាំ x ៨០/១០០

ដូចនេះមធ្យមភាគពិន្ទុវិជ្ជាសម្បទាប្រចាំឆ្នាំ = ៣៥.៨៣ x ៨០/១០០ = ២៨.៦៦

**គ.២. ១០% នៃពិន្ទុបំណិនសម្បទាប្រចាំឆ្នាំ = ចំនួនកិច្ចការ/សកម្មភាពដែលបានអនុវត្ត x $\frac{៥០}{\text{ចំនួនកិច្ចការ ឬសកម្មភាពដែលបានគ្រោង}}$ x $\frac{១០}{១០០}$**

គ្រឹះស្ថានសិក្សាដែលបានរៀបចំឱ្យមានកម្មវិធីក្រៅម៉ោងសិក្សា ការផ្ដល់ពិន្ទុបន្ថែមដល់ម្នាក់ៗយ៉ាងច្រើន ៥ពិន្ទុមធ្យមភាគ ស្មើនឹង ១០% ។

គ្រូទទួលបន្ទុកថ្នាក់នៅដំណាច់ឆ្នាំសិក្សាត្រូវ~~វាយតម្លៃលើបំណិនសម្បទាប្រចាំឆ្នាំរបស់សិស្សម្នាក់ៗ~~ ផ្តោតលើការអនុវត្តកម្មវិធីក្រៅម៉ោងលើសកម្មភាពទាំង១៥ដូចខាងក្រោម៖ ១.បង្រៀនបន្ថែមម៉ោងតាមមុខវិជ្ជាគោលភាសាខ្មែរ( ការពង្រឹងការសរសេរតាមអាននិងតែងសេចក្តី គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ប្រវត្តិវិទ្យា និងភាសាបរទេស) ២. ការអប់រំឱ្យដីថល ៣.អំណានក្នុងបណ្ណាល័យ ៤. ពង្រឹងការសរសេរតាមអាន តែងសេចក្តី គណិតវិទ្យា និងវិទ្យាសាស្ត្រ ៥.ការស្រាវជ្រាវជាគម្រោង ៦.ការរៀបចំឱ្យសិស្សស្វ័យសិក្សា ក្លឹបសិក្សា (ស្វ័យសិក្សាបន្ថែមក្នុងបណ្ណាល័យ តាមក្លឹបសិក្ស តាមបណ្តុំ និងនៅផ្ទះអានសៀវភៅ ឬសន្លឹកកិច្ចការ ឬធ្វើកិច្ចការផ្ទះ និងឯកសារផ្សេងៗទៀត) ៧. ជួយសិស្សរៀនយឺត ៨. ការរៀបចំកម្មវិធីទស្សនកិច្ចសិក្សា / ការរៀបចំកម្មវិធីចុះសង្កេតការងារ ៩. ការងារស្ម័គ្រចិត្ត និងអភិវឌ្ឍបំណិនទន់ ១០. ការអប់រំតាមបែបសាសនា ១១. ការអប់រំចរិយាធម៌ ១២. ការអប់រំសុខភាព ១៣.ប្រឹក្សាអាជីព ១៤. បំណិនជីវិតតាមមូលដ្ឋាន១៥. កម្មវិធីអភិវឌ្ឍយុវជន ។ **ឧទាហរណ៍៖** សិស្ស «ក» ចូលរួមអនុវត្តកម្មវិធីក្រៅម៉ោងសិក្សាបាន ៨ សកម្មភាព/កិច្ចការ ក្នុងចំណោម ១៥ សកម្មភាព/កិច្ចការ ។

- ១០% នៃពិន្ទុបំណិនសម្បទាប្រចាំឆ្នាំ = ៨ x $\frac{៥០}{១៥}$ x $\frac{១០}{១០០}$ = ២.៦៧

គ.៣. ១០% នៃពិន្ទុចរិយាសម្បទាប្រចាំឆ្នាំ = ពិន្ទុចរិយាសម្បទាប្រចាំឆ្នាំ x $\frac{៥០}{៧៨}$ x $\frac{១០}{១០០}$

គ្រូទទួលបន្ទុកថ្នាក់ត្រូវវាយតម្លៃលើចរិយាសម្បទាសិស្សម្នាក់ៗនៅដំណាច់ឆ្នាំសិក្សាដោយប្រើឧបករណ៍វង្វាយតម្លៃសីលធម៌សិស្សានុសិស្សនៅតាមគ្រឹះស្ថានសារធារណៈ។ ពិន្ទុមធ្យមភាគចរិយាសម្បទា ត្រូវយក ពិន្ទុសរុបតាមសូចនាករនីមួយៗ បូកបញ្ចូលគ្នា រួចចែកនឹងចំនួនសូចនាករសរុប ។

ឧទាហរណ៍៖ ពិន្ទុចរិយាសម្បទានៃឧបករណ៍វាយតម្លៃប្រចាំឆ្នាំសិស្ស “ ក ” ទទួលបានពិន្ទុ ៧៣ ។

ដូចនេះ ១០% នៃពិន្ទុចរិយាសម្បទាសប្រចាំឆ្នាំ = ៧៣ x ៥០/៧៨ x ១០/១០០ = ៤.៦៨

ពិន្ទុមធ្យមភាគបប្រចាំឆ្នាំ សិស្ស “ ក ” = ២៨.៦៦ + ២.៦៧ + ៤.៦៨ = ៣៦.០១

**ត.៤.** ការបញ្ចូលពិន្ទុ វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ទៅក្នុងសៀវភៅសិក្ខាគារិក ត្រូវបញ្ចូលនៅត្រង់ចំណុច «**ម**» **មូលវិចាររបស់គ្រូទទួលបន្ទុកថ្នាក់** ដោយសរសេរថា៖ ឧទាហរណ៍៖សិស្ស «**ក**» ទទួលបានពិន្ទុ៖

| | | | |
|---|---|---|---|
| ១ | ពិន្ទុមធ្យមភាគវិជ្ជាសម្បទា | ២៨.៦៦ | មូលវិចាររបស់គ្រូទទួលបន្ទុកថ្នាក់ |
| ២ | ពិន្ទុបំណិនសម្បទា | ២.៦៧ | |
| ៣ | ពិន្ទុចរិយាសម្បទា | ៤.៦៨ | ............................................................................ |
| សរុប | ពិន្ទុមធ្យមភាគប្រចាំឆ្នាំ | ៣៦.០១ | ............................................................................ ............................................................................ ............................................................................ |

ឬគណៈគ្រប់គ្រងសាលារៀនត្រូវរៀបចំត្រាជ្រុងដូចក្នុងគំរូឧទាហរណ៍ខាងក្រោមសម្រាប់គ្រូទទួលបន្ទុកថ្នាក់ ដាក់បញ្ចូលនៅត្រង់ចំណុច «ច»

**ត្រាជ្រុង**

| | | |
|---|---|---|
| ១ | ពិន្ទុមធ្យមភាគវិជ្ជាសម្បទា | ....................................... |
| ២ | ពិន្ទុបំណិនសម្បទា | ....................................... |
| ៣ | ពិន្ទុចរិយាសម្បទា | ....................................... |
| សរុប | ពិន្ទុមធ្យមភាគប្រចាំឆ្នាំ | ....................................... |

# សូមអរគុណ